ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚

ក្រសួងសុខាភិបាល

# សន្និសីទសារព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# បច្ចុប្បន្នភាពជំងឺកូវីដ-១៩ នៅកម្ពុជា
# គិតត្រឹមម៉ោង ០៧:០០ ព្រឹក ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០ បង្ហាញថា មិនមានករណីព្យាបាលជាសះស្បើយ និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នោះទេ។ ដូច្នេះ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- អ្នកព្យាបាលជាសះស្បើយសរុបមានចំនួនកើនឡើងដល់ ១២០នាក់ (ស្មើនឹង ៩៨,៣៦% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣៧នាក់ និងបុរស ៨៣នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិចិន ០២នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្ត្រីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិប៊ែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៩នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ២១នាក់ បុរសជនជាតិកាណាដា ០២នាក់ បុរសជនជាតិម៉ាឡេស៊ី ១៣នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្ត្រីជនជាតិវៀតណាម ០៣នាក់ បុរសជនជាតិខ្មែរ ៤២នាក់ និងស្ត្រីជនជាតិខ្មែរ ០៧នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- អ្នកដែលកំពុងសម្រាកព្យាបាលសរុបបានថយចុះមកនៅចំនួន ០២នាក់ (ស្ត្រី ០១នាក់នៅខេត្តបន្ទាយមានជ័យ និងបុរស ០១នាក់នៅខេត្តកំពង់ឆ្នាំង) ដែលឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានសម្រេចបញ្ជូនមកបន្តការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០។
- អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១២២នាក់ (ស្ត្រី ៣៨នាក់ និងបុរស ៨៤នាក់)។

## ២. មិនមានករណីជាសះស្បើយ និង មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ឡើយ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០។

**៣. ចំនួនសរុបវត្ថុសំណាកដែលបានធ្វើវិភាគ** ទាំងអស់មានចំនួន ១៤,០៩៤សំណាកសម្រាប់ទូទាំងប្រទេស (គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០) ដែលក្នុងចំណោមប្រជាជនមួយលាននាក់ កម្ពុជាបានធ្វើតេស្តបានចំនួន ៨៦៧សំណាក ដែលជាចំនួនច្រើនជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ានយើងនេះ។

**៤. វិធានការធ្វើចត្តាឡីស័ក សម្រាប់អ្នកដំណើរចូលមកកម្ពុជា**

ក្រសួងសុខាភិបាល សូមជម្រាបជូនថា តាមស្ថានភាពនៃការឆ្លងវីរុសកូវីដ-កន្លងមកនេះ ភាគច្រើននៃករណីដែលបានរកឃើញថាមានវីរុសនេះ សុទ្ធសឹងជាករណីដែលនាំចូលមកពីក្រៅប្រទេស ដែលយើងត្រូវបន្តការយកចិត្តទុកដាក់លើវិធានការរឹតបន្តឹងការធ្វើដំណើរមកពីប្រទេសដែលមានការឆ្លងច្រើន ដូចជាប្រទេសអាមេរិក អ៊ីតាលី អាល្លឺម៉ង់ អេស្ប៉ាញ បារាំង និងអ៊ីរ៉ង់ ហើយការរឹតបន្តឹងនេះ បានពន្យាសុពលភាពរហូតដល់ស្ថានភាពនៃការឆ្លងវីរុសនេះ មានការធូរស្រាលដោយមានការវាយតម្លៃរួមគ្នាជាមួយអង្គការសុខភាពពិភពលោក។ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ចូលរួមអនុវត្តវិធានការចត្តាឡីស័កចំនួន ១៤ ថ្ងៃនេះ ឲ្យបានខ្ជាប់ខ្ជួន ដើម្បីចូលរួមចំណែកការពារកុំឲ្យមានការចម្លងវីរុសកូវីដ-១៩ មកក្នុងប្រទេសកម្ពុជា និងសូមអាជ្ញាធរពាក់ព័ន្ធ សហការបន្តអនុវត្តន៍ការតាមដានអ្នកដំណើរចូលមកក្នុងប្រទេស និងអនុវត្តន៍ការធ្វើចត្តាឡីស័កនេះ ឲ្យមានប្រសិទ្ធិភាពខ្ពស់។

**៥. វិធានការដែលត្រូវប្រកាន់យកជាបន្ត ៖**

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការកត់សម្គាល់ថា មកទល់ពេលនេះ ស្ថានភាពជំងឺកូវីដ-១៩ នៅលើសកលលោក នៅតែមានការកើនឡើង និង នៅតែមានរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មីបន្ថែមទៀត ដែលធ្វើឲ្យចំនួនអ្នកមានវីរុសកូវីដ-១៩ បានកើនឡើងរហូតទៅដល់ ៣,៨៥៥,៧៨៨នាក់ បើធៀបទៅនឹងសប្តាហ៍មុនដែលមាន ៣,២៦៧,១៨៤នាក់ នោះ គឺមានការកើនចំនួនរហូតដល់ ៥៨៨,៦០៤នាក់ និងមានអ្នកស្លាប់ចំនួន ២៦៥,៨៦២នាក់ ដែលក្នុងសប្តាហ៍មុនមាន ២២៩,៩៧១នាក់ គឺកើនចំនួនអ្នកស្លាប់ដល់ទៅ ៣៥,៨៩១នាក់ គ្រាន់តែមួយសប្តាហ៍កន្លងទៅ នេះបើយោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ចេញផ្សាយនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០។ នេះ បានបញ្ជាក់ច្បាស់ថា ការចម្លងវីរុសកូវីដ-១៩ នៅតែសកម្មខ្លាំងក្លានៅឡើយ ដែលយើងទាំងអស់គ្នា ត្រូវយល់ថា យើងកំពុងតែបន្តធ្វើសង្គ្រាមជាមួយសត្រូវកូវីដ-១៩ នេះមិនទាន់ចប់នៅឡើយទេ។ សម្រាប់ប្រទេសកម្ពុជា ក្នុងរយៈពេលជិតមួយខែកន្លងមកនេះ មិនមានរកឃើញអ្នកឆ្លងវីរុសកូវីដ-១៩ ថ្មី ហើយអ្នកព្យាបាលជាសះស្បើយក៏បានកើនដល់ជិត ១០០% និងមិនមានស្លាប់នោះឡើយ។ លទ្ធផលល្អប្រសើរនេះ ជាការបង្ហាញថា អន្តរាគមន៍បុរេសកម្ម និងបទបញ្ជានានា ត្រូវបានអនុវត្តបានទាន់ពេលវេលា ដែលអាចឲ្យទប់ស្កាត់បាននូវការចម្លងចូលក្នុងសហគមន៍ ក្រោមការយកចិត្តទុកដាក់ខ្ពស់បំផុតលើសុខភាពប្រជាពលរដ្ឋកម្ពុជា ព្រមទាំងការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ក្នុងន័យនេះ ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានក្រើនរំលឹកថា យើងទាំងអស់គ្នា ត្រូវតែបន្តរក្សាកុំឲ្យមានការចម្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ហើយសូមបងប្អូនប្រជាពលរដ្ឋទាំងអស់ បង្កើន និង បន្តការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវ និង ការប្រុងប្រយ័ត្នខ្ពស់បំផុត មិនត្រូវភ្លេចខ្លួនចំពោះលទ្ធភាពដែលអាចកើតមានឡើងនូវរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ នេះឲ្យសោះ ដោយត្រូវ

ខិតខំបន្តអនុវត្តវិធានការការពារខ្លួនគ្រប់បែបយ៉ាងទាំងអស់ តាមការណែនាំនានាដែលបានដាក់ចេញដោយប្រមុខរាជរដ្ឋាភិបាល និងដោយក្រសួងសុខាភិបាល។ លើសពីនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចេះផ្លាស់ប្តូរឥរិយាបទ និង ទម្លាប់របស់ខ្លួន យើងត្រូវខិតខំប្រឹងប្រែងរៀបចំការ រស់ទៅតាមគន្លងថ្មីនៃជីវភាពធម្មតារបស់ខ្លួន ដោយមិនភ្លេចការធ្វើអនាម័យដៃស្អាត ប្រើប្រាស់ម៉ាស់ (ក្នុងករណីចាំបាច់) ឬក្រម៉ា ឬកន្សែងដៃ ខ្ទប់មាត់ និង ច្រមុះ នៅពេលក្អកកណ្តាស់ បរិភោគចំណីអាហារឆ្អិនល្អ ចៀសវាងនៅកន្លែងប្រមូលផ្តុំច្រើនគ្នា រក្សាគម្លាតសុវត្ថិភាពសង្គម និង គម្លាតសុវត្ថិភាពបុគ្គល នៅតាមកន្លែងប្រមូលផ្តុំ និងនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ឬហាងនានា ហើយប្រសិនបើមានករណីសង្ស័យ ត្រូវរាយការណ៍ទៅលេខ ១១៥ ជាបន្ទាន់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។ ក្រសួង ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ** (TYDA) កាកបាទក្រហមកម្ពុជា សប្បុរសជននានា បណ្តាប្រទេសសហប្រតិបត្តិការអន្តរជាតិទ្វេភាគី និងពហុភាគី ព្រមទាំងដៃគូអង្គការជាតិនិងអន្តរជាតិទាំងអស់ ដែលបានចូលរួមចែករំលែកធនធាន ជាថវិកា សម្ភារៈ និងបរិក្ខាពេទ្យ សម្រាប់យុទ្ធនាការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ០៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០**

**ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ១២២ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល

*សំគាល់៖ អ្នកជំងឺពីខេត្ត បន្ទាយមានជ័យ ចំនួន ០១នាក់ និងខេត្ត កំពង់ឆ្នាំង ចំនួន ០១នាក់ បានប្ដូរមកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




*សំគាល់៖ អ្នកជំងឺពីខេត្ត បន្ទាយមានជ័យ ចំនួន ០១នាក់ និងខេត្ត កំពង់ឆ្នាំង ចំនួន ០១នាក់ បានប្តូរមកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត*

ប្រភព៖ ក្រសួងសុខាភិបាល